# សុន្ទរកថា

# លោកជំទាវ តាល់ ណៃអ៊ីម អគ្គនាយក ធនាគារជាតិនៃកម្ពុជា

# ក្នុងឱកាសបើកវគ្គសិក្ខាសាលាស្តីពីការិយាល័យឥណទានឯកជននៅកម្ពុជា

*ថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០០៨*



## សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា

ថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងមានសេចក្តីសោមនស្សរីករាយដែលបានចូលរួមវគ្គសិក្ខាលាស្តីពីការិយាល័យឥណទានឯកជននៅកម្ពុជា នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ នាពេលនេះ។ នេះជាសិក្ខាសាលាលើកទីពីរដែលពាក់ព័ន្ធនឹងការិយាល័យឥណទាន ដែលបានសហការរៀបចំដោយធនាគារជាតិនៃកម្ពុជា និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ក្នុងគោលបំណងផ្សព្វផ្សាយអំពីលទ្ធផលនៃការសិក្សាដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិលើការប្រើប្រាស់ប្រព័ន្ធចែករំលែកព័តិមានឥណទាន ការផ្តល់អនុសាសន៏ និងលទ្ធភាពនៃការបង្កើតឱ្យមានការិយាល័យឥណទានឯកជននៅកម្ពុជា ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដែលបានចូលរួមទាំងស្មារតី និងសម្ភារៈក្នុងការរៀបចំសិក្ខាសាលាដ៏មានអត្ថប្រយោជន៏នេះ ហើយក៏សូមថ្លែងអំណរគុណផងដែរចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងតំណាងស្ថាប័នពាក់ព័ន្ធនានា ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសជាទីស្នេហា

ខ្ញុំសូមជំរាបអង្គសិក្ខាសាលាជ្រាបថា ដោយមានជំនួយពីធនាគារអភិវឌ្ឍន៏អាស៊ី ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធចែករំលែកព័តិមានឥណទានសម្រាប់គ្រឹះស្ថានធនាគារអនុវត្ត កាលពីឆ្នាំ ២០០៦ ។ ប៉ុន្តែ ការអនុវត្តប្រព័ន្ធនេះមិនទាន់ទទួលបានជោគជ័យនិងមានប្រសិទ្ធភាពនោះទេ ដោយសារ

ប្រព័ន្ធនេះយឺតមានទំហំតូច ហើយឈរលើមូលដ្ឋានប្រើប្រាស់ដោយស្ម័គ្រចិត្តពីអ្នកចូលរួម។ បច្ចុប្បន្ន ប្រព័ន្ធនេះកំពុងតែកែលម្អឡើងវិញ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់គ្រឹះស្ថានធនាគារ។ ថ្វីត្បិតតែ ការប្រើប្រាស់ប្រព័ន្ធនេះជួបប្រទះនូវការលំបាកខ្លះក្តី ប៉ុន្តែខ្ញុំកត់សំគាល់ថា អ្នកប្រើប្រាស់ទាំងអស់យល់ថាប្រព័ន្ធចែករំលែកព័ត៌មានឥណទានពិតជាមានអត្ថប្រយោជន៍ ដែលអាចឱ្យធនាគារងាយស្រួលក្នុងការវិភាគ និងវាយតម្លៃអតិថិជនមុននឹងសម្រេចផ្តល់ឥណទាន ។ ដូច្នេះ ការបង្កើតឱ្យមានការិយាល័យឥណទានឯកជនជាការចាំបាច់ ដែលអាចឱ្យអ្នកប្រើប្រាស់មានលទ្ធភាពវិភាគនិងស្វែងយល់អំពីប្រវត្តិ និងលក្ខណៈសម្បត្តិរបស់អតិថិជនខ្លួន ដើម្បីជួយកាត់បន្ថយហានិភ័យនានាដែលអាចកើតមាន ។

ការបង្កើតការិយាល័យឥណទានឯកជននៅកម្ពុជា គឺជាជំហ៊ានមួយដ៏សំខាន់សំរាប់អនាគតនៃប្រព័ន្ធហិរញ្ញវត្ថុនិងធនាគារនៅកម្ពុជា ។ ការិយាល័យឥណទានជាធាតុមួយយ៉ាងសំខាន់នៃហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុដែលជួយសម្រួលដល់ការទទួលបានសេវាហិរញ្ញវត្ថុ ។ ការិយាល័យឥណទាននឹងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សកម្មភាពឥណទាននៅកម្ពុជាឱ្យកាន់តែមានភាពរីកចំរើននិងទូលំទូលាយ ជាពិសេសគឺការអភិវឌ្ឍន៍សកម្មភាពសេដ្ឋកិច្ចរបស់សហគ្រាសខ្នាតតូចនិងមធ្យម និងការអភិវឌ្ឍន៍វប្បធម៌ព័ត៌មានឥណទានមួយក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា ។ ដូច ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាបានជ្រាបហើយថា ប្រជាជនប្រមាណតែ ១០ភាគរយប៉ុណ្ណោះមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុពីប្រព័ន្ធហិរញ្ញវត្ថុផ្លូវការនៅកម្ពុជា ក្រៅពីនេះ គាត់ត្រូវស្វែងរកហិរញ្ញប្បទានពីអ្នកឱ្យខ្ចីចងការក្រៅផ្លូវការផ្សេងៗទៀត ដែលមានអត្រាការប្រាក់ខ្ពស់ហួសហេតុដែលអាចធ្វើឱ្យប៉ះពាល់ដល់ដំណើរការអាជីវកម្ម ក៏រីតជីវភាពរបស់ប្រជាជន និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ ព្រោះថា សេដ្ឋកិច្ចកម្ពុជាជាសេដ្ឋកិច្ចដែលបានមកពីការចូលរួមយ៉ាងធំធេងពីសហគ្រាស ធុនតូចនិងមធ្យម ហើយការផ្តល់ហិរញ្ញប្បទានដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដល់អ្នកខ្ចីប្រាក់ផ្តោតជាសំខាន់លើសមត្ថភាពសងប្រាក់របស់អតិថិជន និងទាមទារឱ្យមានការដាក់បញ្ចាំនូវវត្ថុធានា នានាដែលអតិថិជនមាន ដូចជាកម្មសិទ្ធិដីធ្លី ឬផ្ទះ ។ ប៉ុន្តែ ករណីកម្មសិទ្ធិដីធ្លី ឬផ្ទះ គឺជាការប្រឈមមួយយ៉ាងសំខាន់ របស់ប្រជាពលរដ្ឋ និងសហគ្រាសធុនតូចនិងមធ្យម ។

វិបត្តិហិរញ្ញវត្ថុជាសកលនាពេលបច្ចុប្បន្ននេះ បានបង្ហាញអំពីសារៈសំខាន់នៃប្រព័ន្ធការិយាល័យឥណទានដែលទាមទារឱ្យមានការបណ្តុះបណ្តាលចំពោះអ្នកខ្ចីប្រាក់ និងការទទួលការខុសត្រូវក្នុងការផ្តល់ឥណទាន។ តើត្រូវធ្វើអ្វីខ្លះដើម្បីចៀសវាងការមានបំណុលច្រើនលើសលប់របស់អ្នកខ្ចីប្រាក់? តើការិយាល័យឥណទានដែលជាអ្នកផ្តល់សេវានិងព័ត៌មានមានតួនាទីអ្វីខ្លះ? តើត្រូវមានបទប្បញ្ញត្តិអ្វីខ្លះដើម្បីឱ្យដំណើរការការិយាល័យឥណទាននិងដោះស្រាយបញ្ហាទាំងនេះ? តើត្រូវធ្វើអ្វីខ្លះដើម្បីធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងជាសាធារណៈ ជាពិសេសចំពោះប្រជាពលរដ្ឋមានចំណូលទាប? តាមរយៈនេះ តើការិយាល័យឥណទានពិតជាមានសារៈសំខាន់យ៉ាងណាខ្លះ ចំពោះស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅកម្ពុជា នាដំណាក់កាលបច្ចុប្បន្ន ។

ឆ្លៀតឱកាសនៃអង្គសិក្ខាសាលា ខ្ញុំសូមលើកឡើងនូវបញ្ហាមួយចំនួន ដែលជាចំណុចសំខាន់ៗទាក់ទងដល់ប្រតិបត្តិការរបស់ការិយាល័យឥណទាននៅពេលអនាគត ដើម្បីជូនអង្គសិក្ខាសាលាពិនិត្យពិចារណា រួមមានៈ

១-ការចូលជាសមាជិកការិយាល័យឥណទាន ជាកាតព្វកិច្ច

២-ការបញ្ចូលព័ត៌មានទាំងអស់ រួមទាំងព័ត៌មានឥណទានវិជ្ជមាននិងអវិជ្ជមាន ដោយពុំមានកំណត់ពិដានចំនួនប្រាក់

៣-ការចូលរួមរបស់ក្រុមហ៊ុនមិនមែនធនាគារនៅក្នុងប្រព័ន្ធ ដូចជា ក្រុមហ៊ុនភតិសន្យា ក្រុមហ៊ុនទឹកនិងអគ្គិសនី ជាដើម ។

ខ្ញុំសង្ឃឹមថា នឹងទទួលបាននូវមតិរបស់សមាជិកអង្គសិក្ខាសាលា ក៏ដូចជាអនុសាសន៍របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាលាយលក្ខអក្សរផ្ញើមកធនាគារជាតិនៃកម្ពុជាឱ្យបានឆាប់រហ័ស លើបញ្ហាទាំងបីខាងលើនេះ ដើម្បីយើងមានមូលដ្ឋានបញ្ចូលទៅក្នុងបទប្បញ្ញត្តិ ដែលយើងនឹងត្រូវរៀបចំនៅពេលអនាគតនេះ ។

ក្រៅពីនេះ ខ្ញុំក៏សូមជំរាបជូនដំណឹងផងដែរថា ជាជំហ៊ានបន្ទាប់ពីការសិក្សាអំពីលទ្ធភាពបង្កើតការិយាល័យឥណទាននេះ ធនាគារជាតិនៃកម្ពុជាដោយសហការជាមួយ IFC នឹងបង្កើតឡើងនូវក្រុមការងារមួយដែលមានសមាជិកចូលរួមពីធនាគារជាតិនៃកម្ពុជា IFC និងតំណាងឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រាប់រៀបចំការងារយោងតាមផែនការសកម្មភាពការងារដ៏ច្បាស់មួយ ដើម្បីឈានដល់ការបង្កើតឡើងនូវការិយាល័យឥណទាននេះ។ ដូច្នេះ ខ្ញុំសូមឱ្យសមាគមធនាគារកម្ពុជានិងសមាគមមីក្រូហិរញ្ញវត្ថុត្រៀមបញ្ជូនតំណាងដែលមានសមត្ថភាពជជែកពិភាក្សាចូលរួមក្នុងក្រុមការងារនេះ។ ចំពោះចំនួនតំណាងនៅក្នុងសមាគមនីមួយៗ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងនាពេលក្រោយ ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសជាទីស្នេហា**

ខ្ញុំសង្ឃឹមថា វត្តមានឯកឧត្តម លោក លោកស្រី នាងកញ្ញា នាពេលនេះ នឹងចូលរួមពិភាក្សាយ៉ាងផុសផុលលើប្រធានបទនេះ និងអនុសាសន៍នានា ដើម្បីស្វែងរកវិធីសាស្ត្រ ដំណោះស្រាយ និងលទ្ធភាពការបង្កើតឱ្យមានការិយាល័យឥណទានឯកជននៅកម្ពុជា ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានវត្តមានក្នុងសិក្ខាសាលាថ្ងៃនេះសូមមានសុខភាពល្អ និងមានជោគជ័យក្នុងការងារ និងសង្ឃឹមថាសិក្ខាសាលានេះនឹងទទួលបានលទ្ធផលជាផ្លែផ្កា ដើម្បីជាមូលដ្ឋានគាំទ្រដល់ការអភិវឌ្ឍន៍ប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា ស្របតាមយុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ ២០០៦-២០១៥។

ខ្ញុំសូមប្រកាសបើកវគ្គសិក្ខាសាលាស្តីពី ការិយាល័យឥណទានឯកជននៅកម្ពុជា ជាផ្លូវការចាប់ពីពេលនេះតទៅ ។

***សូមអរគុណ***